# និយ័តករគណនេយ្យនិងសវនកម្ម

## ព្រឹត្តិបត្រព័ត៌មានប្រចាំខែសីហា ឆ្នាំ២០២៤

លេខ:០០៨

សេចក្តីសង្ខេបព័ត៌មាន និងព្រឹត្តិការណ៍សំខាន់ៗប្រចាំខែសីហារបស់និយ័តករគណនេយ្យ និងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រួមមានដូចខាងក្រោម៖

## កិច្ចប្រជុំក្រុមការងារមណ្ឌលហិរញ្ញវត្ថុ ដើម្បីពិភាក្សាលើកិច្ចការពាក់ព័ន្ធនឹងមណ្ឌលហិរញ្ញវត្ថុ




១.កាលពីថ្ងៃពុធ ១១រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣១ ខែកក្កដា គ.ស. ២០២៤ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី នាន បូនី** អគ្គនាយករង និង **លោកស្រី ថោ សេដ្ឋចាន់លីដា** អនុប្រធាន-នាយកដ្ឋានកិច្ចការទូទៅបានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមការងារមណ្ឌលហិរញ្ញវត្ថុ ដើម្បីពិភាក្សាលើកិច្ចការពាក់ព័ន្ធនឹងមណ្ឌលហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក.ស.ហ.វ) និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ព្រមទាំងជាប្រធានក្រុមការងារមណ្ឌលហិរញ្ញវត្ថុ។

## កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ



### ព័ត៌មានថ្មីៗ

កិច្ចប្រជុំក្រុមការងារ សូមអាននៅទំព័រ......................១
កិច្ចប្រជុំ សូមអាននៅទំព័រ..................................២
កម្មវិធីទូងស្គរ សូមអាននៅទំព័រ ............................២
សិក្ខាសាលា សូមអាននៅទំព័រ.................................២
កិច្ចពិភាក្សា សូមអាននៅទំព័រ...............................៣
វគ្គបណ្តុះបណ្តាល សូមអាននៅទំព័រ.........................៤
កិច្ចសម្របសម្រួល សូមអាននៅទំព័រ.........................៤
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ.........................៥
វគ្គបណ្តុះបណ្តាល សូមអាននៅទំព័រ.........................៥
កិច្ចប្រជុំបច្ចេកទេស សូមអាននៅទំព័រ......................៦
កិច្ចសហប្រតិបត្តិការ សូមអាននៅទំព័រ.....................៦
សិក្ខាសាលា សូមអាននៅទំព័.................................៧
ការបង្ហាញខ្លួន សូមអាននៅទំព័រ.............................៧
កិច្ចប្រជុំបច្ចេកទេស សូមអាននៅទំព័រ......................៨
កិច្ចប្រជុំកម្រិត សូមអាននៅទំព័រ............................៨
វគ្គបណ្តុះបណ្តាល សូមអាននៅទំព័រ.........................៩
កិច្ចប្រជុំវេទិកា សូមអាននៅទំព័រ............................៩
កិច្ចប្រជុំអន្តរ សូមអាននៅទំព័រ.............................១០
សិក្ខាសាលាសូមអាននៅទំព័រ.................................១០
សិក្ខាសាលា សូមអាននៅទំព័រ................................១១
ការធ្វើបទបង្ហាញ សូមអាននៅទំព័រ..........................១២
សិក្ខាសាលា សូមអាននៅទំព័រ................................១២
កិច្ចប្រជុំ សូមអាននៅទំព័រ....................................១៣
កិច្ចប្រជុំបច្ចេកទេស សូមអាននៅទំព័រ.....................១៣
ការប្រឡង សូមអាននៅទំព័រ...................................១៤
កិច្ចប្រជុំក្រុមការងារ សូមអាននៅទំព័រ.....................១៤
វគ្គបណ្តុះបណ្តាល សូមអាននៅទំព័រ........................១៥
សិក្ខាសាលា សូមអាននៅទំព័រ................................១៥
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ.........................១៦
កិច្ចប្រជុំស្តីពី សូមអាននៅទំព័រ..............................១៦
កម្មវិធីចុះហត្ថលេខា សូមអាននៅទំព័រ.....................១៧

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

២.កាលពីថ្ងៃព្រហស្បតិ៍ ១២រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១ ខែសីហា គ.ស. ២០២៤ នៅធនាគារជាតិនៃកម្ពុជា **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី ថោ សេដ្ឋចាន់លីដា** អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការដឹកនាំ ការងារអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ដើម្បីពិភាក្សាលើសេចក្តីព្រាងចុងក្រោយនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០២១-២០៣០ ក្រោមអធិបតីភាពរបស់ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា ព្រមទាំង ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាអនុប្រធាន និង សមាជិក នៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ។

## កម្មវិធីទូងស្គរដើម្បីអបអរសាទរពិធីបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ



៣.កាលពីថ្ងៃចន្ទ ១កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែសីហា គ.ស.២០២៤ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម បានអញ្ជើញចូលរួមកម្មវិធីទូងស្គរដើម្បីអបអរសាទរពិធីបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## សិក្ខាសាលាផ្សព្វផ្សាយ "ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ ជូនសាស្ត្រាចារ្យនិងនិស្សិត នៃវិទ្យាស្ថានវ៉ាន់ដា រាជធានីភ្នំពេញ



៤.កាលពីថ្ងៃពុធ ៣កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែសីហា គ.ស. ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានសហការជាមួយវិទ្យាស្ថានវ៉ាន់ដា រៀបចំសិក្ខាសាលាផ្សព្វផ្សាយ "ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ ជូនសាស្ត្រាចារ្យនិងនិស្សិត នៃវិទ្យាស្ថានវ៉ាន់ដា រាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមនៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព។ សិក្ខាសាលានេះក៏មានការអញ្ជើញចូលរួមពី **ឯកឧត្តមបណ្ឌិត ហេង វ៉ាន់ដា** ប្រធាន

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

ក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានវ៉ាន់ដាព្រមទាំង **លោកស្រី សារុជ ដាលី** នាយកប្រតិបត្តិ នៃវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ព្រមទាំង លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងថ្នាក់ដឹកនាំ មន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម ចំនួន៣៨១នាក់។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយនិងបញ្ជ្រាបការការយល់ដឹង អំពីច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងគណនេយ្យនិងសវនកម្ម ព្រមទាំងស្តង់ដាបច្ចេកទេសនៅកម្ពុជាដល់សាស្ត្រាចារ្យនិងនិស្សិត ដែលកំពុងសិក្សាជំនាញពាក់ព័ន្ធ។

## កិច្ចប្រជុំលើកទី៤ របស់អនុគណៈកម្មាធិការអភិវឌ្ឍកម្មវិធីសិក្សានៃគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា




៥.កាលពីថ្ងៃពុធ ៣កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែសីហា គ.ស.២០២៤ **លោក ហុង ពិសិដ្ឋ** ប្រធានអនុគណៈកម្មាធិការអភិវឌ្ឍកម្មវិធីសិក្សា បានដឹកនាំកិច្ចប្រជុំលើកទី៤ របស់អនុគណៈកម្មាធិការអភិវឌ្ឍកម្មវិធីសិក្សានៃគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ដោយមានការអញ្ជើញចូលរួមពី លោក លោកស្រី ដែលជាសមាជិក និងក្រុមលេខាធិការដ្ឋាន។ គោលបំណងនៃកិច្ចប្រជុំនេះដើម្បីជ្រើសរើសសៀវភៅសិក្សាសម្រាប់ឆមាសទី២ គ.ស. ២០២៤ ដោយស្របតាមផែនការសកម្មភាពប្រចាំឆ្នាំ ក្នុងការដាក់ឱ្យដំណើរការនៃការចុះឈ្មោះចូលរៀនកម្មវិធីសិក្សាដល់សាធារណជន សិស្សនិស្សិត សម្រាប់ឆមាសទី២ គ.ស.២០២៤។

## វគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម" CIFRS for SMEs



៦.កាលពីថ្ងៃព្រហស្បតិ៍ ៤កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី០៨ ខែសីហា គ.ស. ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី “ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម” វគ្គទី៧ រយៈពេល៦ថ្ងៃនៅ អគារ ៣៤៥។ វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី នាន បូនី** អគ្គនាយករង ព្រមទាំង **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួល បន្ទុករួមនៃនាយកដ្ឋានកិច្ចការគតិយុត្ត និងអនុលោមភាព វគ្គបណ្តុះបណ្តាលនេះក៏មានការអញ្ជើញចូលរួមពី **លោក សាយ សុខខេង** អគ្គនាយកក្រុមហ៊ុន DFC ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រី នៃនិយ័តករគណនេយ្យនិងសវនកម្ម ក្នុងនោះសម្រាប់វគ្គនេះក៏មានការចុះឈ្មោះចូលរួមពីសំណាក់ក្រុមហ៊ុនសហគ្រាស និងបុគ្គលជាប់កាតព្វកិច្ចទទួលខុសត្រូវលើកិច្ចការគណនេយ្យសរុបចំនួន៥០នាក់។ វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងនៅក្នុងគោលដៅបញ្ជ្រាបការយល់ដឹងនិងសិក្សាលម្អិតលើបច្ចុប្បន្នភាព លក្ខខណ្ឌតម្រូវនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម ដែលជាមូលដ្ឋានក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងសម្រាប់ការចូលរួមអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្ម ដូចមានចែងក្នុងច្បាប់ស្តីពីគណនេយ្យនិងសវនកម្មនិងបទប្បញ្ញត្តិពាក់ព័ន្ធ។

## កិច្ចសម្របសម្រួលការងារក្នុងក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា



៧.កាលពីថ្ងៃសុក្រ ៥កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី០៩ ខែសីហា គ.ស. ២០២៤ នៅក្រសួងផែនការ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេស បានដឹកនាំមន្ត្រីជំនាញនៃនាយកដ្ឋានបច្ចេកទេស ចូលជួបពិភាក្សាជាមួយ **ឯកឧត្តម ថេង បញ្ញាធន** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអគ្គនាយកផែនការ នៃអគ្គនាយកដ្ឋានផែនការនៃក្រសួងផែនការ ដើម្បីសិក្សាស្វែងយល់អំពីកិច្ចសម្របសម្រួលការងារក្នុងក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា និងទទួលបានព័ត៌មានបន្ថែមជាពិសេសទិន្នន័យដែលក្រសួងផែនការ អាចមានការពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០។

## កិច្ចប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំជាមួយ អគ្គនាយកដ្ឋានថវិកាលើគម្រោងចំណូលចំណាយឆ្នាំ២០២៥



© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

៨.កាលពីថ្ងៃសុក្រ ៥កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែសីហា គ.ស. ២០២៤ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក ទឹម សត្យា** អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ **លោកស្រី ហា សុគន្ធា** ប្រធានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ និង**លោក យេម ឆៃយ៉ា** អនុប្រធានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំជាមួយ អគ្គនាយកដ្ឋានថវិកា លើកគម្រោងចំណូល-ចំណាយឆ្នាំ២០២៥ ដែលដឹកនាំដោយ **ឯកឧត្តម ចាន់ សុធី** រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## វគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តការងារសវនកម្ម



៩.កាលពីថ្ងៃព្រហស្បតិ៍ ៤កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៨ ខែសីហា គ.ស. ២០២៤ **លោក ជេន ផាត** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យ និងសវនកម្ម បានដឹកនាំថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តការងារសវនកម្ម។ **ន.គ.ស.** បានសហការជាមួយក្រុមហ៊ុន ប្រាយវ៉តធ័រហោវខូភើស៍ (ខេមបូឌា) ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តការងារសវនកម្ម ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ នៃការិយាល័យត្រួតពិនិត្យ។ វគ្គបណ្តុះបណ្តាលនេះមានរយៈពេល ២ ថ្ងៃគឺ ចាប់ពីថ្ងៃទី៨ ដល់ថ្ងៃទី៩ ខែសីហា គ.ស. ២០២៤ ដោយមានគោលដៅផ្តល់ជាធាតុចូលបន្ថែមតាមរយៈការអនុវត្តការងារសវនកម្មជាក់ស្តែងក្នុងនាមជាសវនករ។

## កិច្ចប្រជុំបច្ចេកទេស នៃអង្គភាពក្រោមឱវាទ អ.ស.ហ.




© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

១០.កាលពីថ្ងៃចន្ទ ៨កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១២ ខែសីហា គ.ស. ២០២៤ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី នាន បូនី** អគ្គនាយករង **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេស និង**លោក ពេជ សុភាចារ** មន្ត្រីជំនាញនាយកដ្ឋានបច្ចេកទេស បានចូលរួមកិច្ចប្រជុំបច្ចេកទេស នៃអង្គភាពក្រោមឱវាទ **អ.ស.ហ.** ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា **អ.ស.ហ.** ដើម្បីពិនិត្យនិងផ្តល់យោបល់ទៅលើ៖ "សេចក្តីព្រាងសទ្ធានុក្រមគណនេយ្យនិងសវនកម្ម" ក្នុងក្របខណ្ឌស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម សរុបចំនួន៥៧៩ វាក្យសព្ទ តាមប្រព័ន្ធអនឡាញ (Zoom)។ ជានីតិវិធីបន្ទាប់ "សទ្ធានុក្រមគណនេយ្យនិងសវនកម្ម" នឹងត្រូវឆ្លងកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** ដើម្បីអនុម័តដាក់ឱ្យប្រើប្រាស់។

## កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹង និងការអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យគណនេយ្យនិងសវនកម្ម នៅព្រះរាជាណាចក្រកម្ពុជា



១១.កាលពីថ្ងៃចន្ទ ៨កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១២ ខែសីហា គ.ស. ២០២៤ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** និយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំពិធីចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយ និងសាកលវិទ្យាល័យពាណិជ្ជសាស្ត្រអេស៊ីលីដា (ស.ព.អ) ស្តីពី "កិច្ចសហប្រតិបត្តិការលើការលើកកម្ពស់ការយល់ដឹង និងការអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យគណនេយ្យនិងសវនកម្ម នៅព្រះរាជាណាចក្រកម្ពុជា"។ **ឯកឧត្តមបណ្ឌិត ម៉ី វ៉ាន់** រដ្ឋលេខាធិការ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន បានអញ្ជើញជាភ្ញៀវកិត្តិយស និងជាសាក្សីនូវការចុះអនុស្សរណៈរវាង **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម តំណាងនិយ័តករគណនេយ្យនិងសវនកម្ម និង **លោកបណ្ឌិត ផុន ណារិន** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យពាណិជ្ជសាស្ត្រអេស៊ីលីដា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំនិយ័តករ និងអង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ព្រមទាំងថ្នាក់ដឹកនាំនិងនិស្សិត នៃសាកលវិទ្យាល័យពាណិជ្ជសាស្ត្រអេស៊ីលីដា។ គោលបំណងនៃការចុះអនុស្សរណៈនៃការយោគយល់នេះផ្តោតសំខាន់ទៅលើកម្មវត្ថុចម្បងចំនួន ៣ ដូចខាងក្រោម៖ ១. ការលើកកម្ពស់ការយល់ដឹង និងផ្សព្វផ្សាយពីវិស័យគណនេយ្យនិងសវនកម្ម, ២. សហការលើការរៀបចំធ្វើបច្ចុប្បន្នភាពលើកម្មវិធីសិក្សា និង៣.ការចាត់អ្នកជំនាញវិជ្ជាជីវៈចូលរួមជាវាគ្មិនកិត្តិយសក្នុងព្រឹត្តិការណ៍ពាក់ព័ន្ធនានាទៅវិញទៅមក។

## សិក្ខាសាលាផ្សព្វផ្សាយ "ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ ជូនសាស្ត្រាចារ្យនិងនិស្សិត នៃសាកលវិទ្យាល័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម



១២.កាលពីថ្ងៃអង្គារ ៩កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៣ ខែសីហា គ.ស. ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានសហការជាមួយសាកលវិទ្យាល័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ "ច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ" ជូនសាស្ត្រាចារ្យនិងនិស្សិត នៃសាកលវិទ្យាល័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម នៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព ព្រមទាំងមានការអញ្ជើញចូលរួមពី **ឯកឧត្តមបណ្ឌិត ជួន រតនៈ** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុព្រមទាំង **លោកស្រី សារុជ ដាលី** នាយកប្រតិបត្តិ នៃវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ព្រមទាំង លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងថ្នាក់ដឹកនាំ មន្ត្រីនៃនិយ័តករគណនេយ្យ និងសវនកម្ម ប្រមាណសរុបចំនួន ១៧០នាក់។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយនិងបញ្ជ្រាបការការយល់ដឹងអំពីច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងគណនេយ្យនិងសវនកម្ម ព្រមទាំងស្តង់ដាបច្ចេកទេសនៅកម្ពុជាដល់សាស្ត្រាចារ្យនិងនិស្សិតដែល កំពុងសិក្សាជំនាញពាក់ព័ន្ធ។

## ការបង្ហាញខ្លួនរបស់បេក្ខជន បេក្ខនារី មន្ត្រីជាប់កិច្ចសន្យា ៥នាក់



១៣.កាលពីថ្ងៃអង្គារ ៩កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៣ ខែសីហា គ.ស. ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំឱ្យមានការបង្ហាញខ្លួនរបស់បេក្ខជន បេក្ខនារី ដែលបានប្រឡងជាប់ស្ពាពជាមន្ត្រីជាប់កិច្ចសន្យា៥រូប មកបម្រើការងារនៅនិយ័តករគណនេយ្យនិងសវនកម្ម និងវគ្គបណ្តុះបណ្តាលតម្រង់ទិស ក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងអំពីតួនាទីភារកិច្ចបទបញ្ជាផ្ទៃក្នុង និងបទដ្ឋានគតិយុត្តអំពីនាយកដ្ឋានទាំងអស់ដែលនៅស្ថិតក្រោមឱវាទរបស់និយ័តករគណនេយ្យនិងសវនកម្ម។ វគ្គបណ្តុះបណ្តាលនេះដែរត្រូវបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម និងលោក លោកស្រី ដែលជាអនុប្រធាននាយកដ្ឋាន និងមន្ត្រី នៃ **ន.គ.ស.** ផងដែរ។

## កិច្ចប្រជុំបច្ចេកទេស នៃអង្គភាពក្រោមឱវាទ អ.ស.ហ.

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម




១៤.កាលពីថ្ងៃពុធ ១០កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៤ ខែសីហា គ.ស. ២០២៤ តាមរយៈប្រព័ន្ធវីដេអូហ្សូម (Zoom) **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី នាន បូនី** អគ្គនាយករង និង **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម ថ្នាក់ដឹកនាំនិងមន្ត្រីជំនាញ នៃ **ន.គ.ស.** បានចូលរួមកិច្ចប្រជុំបច្ចេកទេស នៃអង្គភាពក្រោមឱវាទ អ.ស.ហ. លើកទី២៖ ១.សេចក្តីព្រាងអនុក្រឹត្យស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម, ២.សេចក្តីព្រាងប្រកាសស្តីពីកាតព្វកិច្ចដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារឱ្យស្របតាមស្មារតីនៃកិច្ចប្រជុំបច្ចេកទេសអង្គភាពក្រោមឱវាទ កាលពីថ្ងៃទី៤ ខែកក្កដា គ.ស. ២០២៤។ ជានីតិវិធីបន្ទាប់សេចក្តីព្រាងអនុក្រឹត្យ និងសេចក្តីព្រាងប្រកាសខាងលើ នឹងត្រូវឆ្លងកិច្ចប្រជុំក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## កិច្ចប្រជុំកម្រិតបច្ចេកទេសជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល



១៥.កាលពីថ្ងៃសៅរ៍ ១២កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៤ ខែសីហា គ.ស. ២០២៤ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោកស្រី ថោ សេដ្ឋចាន់លីដា** អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ បានដឹកនាំមន្ត្រីជំនាញ **ន.គ.ស** ចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីល ដើម្បីពិភាក្សាអំពីការរៀបចំក្របខណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ នៅការិយាល័យអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល។

## វគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម" វគ្គទី១ ជូនមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារ



១៦.កាលពីថ្ងៃចន្ទ ១៥កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែសីហា គ.ស. ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សហការជាមួយអគ្គនាយកដ្ឋានពន្ធដារ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម"(CIFRS for SMEs) វគ្គទី១ ជូនមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដាររយៈពេល៥ថ្ងៃ នៅអគារ ៣៤៥។ វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេស វគ្គបណ្តុះបណ្តាលនេះក៏មានការអញ្ជើញចូលរួមពី **ឯកឧត្តម កែន សម្បត្តិ** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម គង់ វិបុល រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ** និងលោក **សាយ សុខខេង** អគ្គនាយកក្រុមហ៊ុនឌីអេស្វស៊ី (DFC) ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម ក្នុងនោះ មានមន្ត្រីនៃនាយកដ្ឋានពន្ធដារសរុបចំនួន៥៣នាក់។ វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងនៅក្នុងគោលដៅបញ្ជ្រាបការយល់ដឹងនិង សិក្សាលម្អិតលើបច្ចុប្បន្នភាពលក្ខខណ្ឌតម្រូវនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម ដែលជាមូលដ្ឋានក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងសម្រាប់ការចូលរួមអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្មដូចមាន ចែងក្នុងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ។

## ការបើកវិញ្ញាសាសម្រាប់ការប្រឡងលើកទី១ លើមុខវិជ្ជា Management Accounting (MAC)



១៧.កាលពីថ្ងៃចន្ទ ១៥កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែសីហា គ.ស. ២០២៤ នៅអគារ ៣៤៥ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាអនុប្រធានប្រចាំការរបស់គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា អមដោយប្រធាន និងសមាជិកនៃអនុគណៈកម្មាធិការគ្រប់គ្រងការប្រឡងបានអញ្ជើញចូលរួមបើកវិញ្ញាសាសម្រាប់ការប្រឡងលើកទី១ លើមុខវិជ្ជា Management Accounting (MAC) ដែលមានបេក្ខជនសរុបចំនួន៧នាក់។

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

## កិច្ចប្រជុំអន្តរអគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ




១៨.កាលពីថ្ងៃចន្ទ ១៥កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែសីហា គ.ស.២០២៤ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃ ន.គ.ស. អមដោយមន្ត្រីជំនាញ បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរអគ្គនាយកដ្ឋាននិងអង្គភាពក្រោមឱវាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីសេចក្តីព្រាងក្របខណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម គង់ ម៉ារី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានប្រចាំការនៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាន តាមប្រព័ន្ធវីដេអូហ្វូម (Zoom) ដោយមានការអញ្ជើញចូលរួមពីតំណាងអគ្គនាយកដ្ឋាន និយ័តករ និងអង្គភាពពាក់ព័ន្ធ។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ" សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ



១៩.កាលពីថ្ងៃអង្គារ ១រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២០ ខែសីហា គ.ស. ២០២៤ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ" សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ។ សិក្ខាសាលានេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ**លោកស្រី នាន បូនី** អគ្គនាយករង និង**លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម នៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម ព្រមទាំងវត្តមានរបស់តំណាងសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញសរុប២០០នាក់។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីកាតព្វកិច្ចគណនេយ្យនិងសវនកម្ម និង

បទប្បញ្ញត្តិពាក់ព័ន្ធ ជូនដល់នាយកក្រុមហ៊ុន សហគ្រាស ប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ និងអ្នកដែលមានការទទួលខុសត្រូវលើកិច្ចការងារគណនេយ្យរបស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "លទ្ធផលនៃការចុះការត្រួតពិនិត្យគុណភាពសវនកម្មសម្រាប់ឆ្នាំ២០២៣ និងទិសដៅការងារបន្តលើកម្មវិធីត្រួតពិនិត្យគុណភាពសវនកម្ម"



២០.កាលពីថ្ងៃព្រហស្បតិ៍ ៣រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹងថ្ងៃទី២២ ខែសីហា គ.ស. ២០២៤ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានសហការជាមួយវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ស្តង់ដាសវនកម្មអន្តរជាតិសម្រាប់សហគ្រាសមិនស្មុគស្មាញនៅកម្ពុជា ( The ISA for LCE In Cambodia )" ក្រោមអធិបតីភាពរបស់ **លោក ជេន ផាត** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម និង **លោក យុន ដារិទ្ធ** ប្រធានក្រុមប្រឹក្សាភិបាលនៃ វ.គ.ស.ក.។ សិក្ខាសាលាពិគ្រោះយោបល់នេះមានការអញ្ជើញចូលរួមពីសមាជិកវិទ្យាស្ថាន វ.គ.ស.ក. មន្ត្រីបច្ចេកទេស និងមន្ត្រីជំនាញការិយាល័យត្រួតពិនិត្យនៃ ន.គ.ស. ដែលមានសិក្ខាកាមសរុប៥០នាក់។ កិច្ចប្រជុំពិគ្រោះយោបល់នេះរៀបចំឡើងក្នុងគោលបំណងប្រជុំពិភាក្សា ដើម្បីប្រមូលធាតុចូលបន្ថែមក៏ដូចជាដើម្បីពិភាក្សាអំពីភាពចាំបាច់ អត្ថប្រយោជន៍ការធ្វើសវនកម្មប្រកបដោយប្រសិទ្ធភាព គុណភាពសវនកម្ម សង្គតិភាព និងភាពអាចជឿទុកចិត្តបាន ព្រមទាំងបញ្ហាប្រឈមនានាពាក់ព័ន្ធទៅនឹងការអនុវត្តស្តង់ដា ISA for LCE ថ្មីនេះនៅកម្ពុជា។បង្កើតឱ្យមានជាវេទិកាពិភាក្សាលើបទពិសោធន៍ដែលបានអនុវត្តកន្លងមក និងការត្រៀមរៀបចំខ្លួនសម្រាប់ពេលអនាគតឱ្យធានាបាននូវគុណភាពសវនកម្មនៅកម្ពុជា។

## ការធ្វើបទបង្ហាញចែករំលែកអំពី "បច្ចុប្បន្នភាពនៃការអនុវត្តកិច្ចបញ្ជិកាគណនេយ្យរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល"




ប្រជុំរបស់អគ្គនាយកដ្ឋានរតនាគារជាតិ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន អគ្គនាយក** នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោកស្រី នាន បូនី** អគ្គនាយករង អមដោយ **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេស និងមន្ត្រីជំនាញនៃ

នាយកដ្ឋានបច្ចេកទេសបានចូលរួមក្នុងការធ្វើបទបង្ហាញចែករំលែកអំពី "បច្ចុប្បន្នភាពនៃការអនុវត្តកិច្ចបញ្ជិកាគណនេយ្យរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល" ដោយតំណាងអគ្គនាយកដ្ឋានរតនាគារជាតិ ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញរបស់និយ័តករគណនេយ្យនិងសវនកម្ម។ ការចែករំលែកនេះត្រូវបានរៀបចំឡើងក្នុងគោលបំណង សិក្សាស្វែងយល់បន្ថែមអំពីកិច្ចបញ្ជិកាគណនេយ្យ របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីជាមូលដ្ឋានក្នុងការរៀបចំសេចក្តីព្រាងស្តង់ដាគណនេយ្យសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល។

## សិក្ខាសាលាស្តីពី "She Trades Outlook Validation Workshop"



២២.កាលពីថ្ងៃចន្ទ ៧រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែសីហា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេស បានចូលរួមសិក្ខាសាលាស្តីពី "She Trades Outlook Validation Workshop" សហការរៀបចំឡើងក្រសួងពាណិជ្ជកម្ម និងមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC) នៅសណ្ឋាគារ Hyatt Regency Phnom Penh ក្រោមអធីបតីភាពដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវ ចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្នុងគោលបំណងពិភាក្សាជាមួយវិស័យសាធារណៈនិងឯកជនអំពីលទ្ធផលនៃការវាយតម្លៃ និងកំណត់រកវិស័យអាទិភាពសម្រាប់កំណែទម្រង់គោលនយោបាយនិងជំនួយបច្ចេកទេស។

## កិច្ចប្រជុំស្តីពីវឌ្ឍនភាពនៃការអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងការធ្វើបច្ចុប្បន្នភាពប្រព័ន្ធ E-filing



២៣. កាលពីថ្ងៃអង្គារ ៨រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៧ ខែសីហា គ.ស.២០២៤ នៅបន្ទប់ប្រជុំធំ ន.គ.ស. **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមនៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាពបានដឹកនាំកិច្ចប្រជុំពិភាក្សាលើការងារសំខាន់ៗចំនួនពីរដូចខាងក្រោម៖ ១.វឌ្ឍនភាពនៃការអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុ មក **ន.គ.ស.**តាមប្រព័ន្ធអនឡាញ (E-Filing)

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

សម្រាប់សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ សម្រាប់ការិយបរិច្ឆេទគណនេយ្យ ២០២០, ២០២១, ២០២២ និង២០២៣។ ២.ការធ្វើបច្ចុប្បន្នភាពប្រព័ន្ធ E-filing សម្រាប់បន្ថែមមុខងារមួយចំនួន ដើម្បីជួយសម្រួលដល់ការប្រើប្រាស់របស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឲ្យកាន់តែមានភាពងាយស្រួលជាងមុន។

## កិច្ចប្រជុំបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ




២៤.កាលពីថ្ងៃអង្គារ ៨ រោច ខែស្រាពណ៍ ឆ្នាំរោង ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៧ ខែសីហា គ.ស.២០២៤ តាមរយៈប្រព័ន្ធវីដេអូហ្សូម (Zoom) និយ័តករគណនេយ្យនិងសវនកម្ម ក្រោមការដឹកនាំដោយ **លោកស្រី នាន បូនី** អគ្គនាយករង តំណាងដ៏ខ្ពស់ខ្ពង់របស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោក លី កុសល** និង**លោក អ៊ីន បុត្រា** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួម និងមន្ត្រីជំនាញនៃ ន.គ.ស. បានចូលរួមកិច្ចប្រជុំបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងអនុក្រឹត្យស្តីពីការធានារ៉ាប់រងខ្នាតតូច។

## ការប្រឡងប្រជែងផ្ទៃក្នុងផ្លាស់ប្តូរប្រភេទមន្ត្រីលក្ខន្តិកៈ សម្រាប់មន្ត្រីលក្ខន្តិកៈ របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ



២៥.កាលពីថ្ងៃពុធ ៩ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែសីហា គ.ស. ២០២៤ និយ័តករគណនេយ្យនិងសវនកម្មបានរៀបចំការប្រឡងប្រជែងផ្ទៃក្នុងផ្លាស់ប្តូរប្រភេទមន្ត្រីលក្ខន្តិកៈសម្រាប់មន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បម្រើការងារនៅនិយ័តករគណនេយ្យនិងសវនកម្មនៅ អគារ ៣៤៥ ដោយមានការអញ្ជើញចូលរួមដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន**

អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាប្រធានគណៈកម្មការរៀបចំការប្រឡង អមដោយលោកអគ្គនាយករង ដែលជាអនុប្រធានគណៈកម្មការ ព្រមជាមួយលោក លោកស្រី អនុប្រធាននាយកដ្ឋាន និងប្រធាន-អនុប្រធានការិយាល័យ ជាសមាជិក។

## កិច្ចប្រជុំក្រុមការងារមណ្ឌលហិរញ្ញវត្ថុលើកទី៨



២៦.កាលពីថ្ងៃពុធ ៩រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែសីហា គ.ស. ២០២៤ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយ **លោកស្រី នាន បូនី** អគ្គនាយករង និង**លោកស្រី ថោ សេដ្ឋចាន់លីដា** អនុប្រធាននាយកដ្ឋាន បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមការងារមណ្ឌលហិរញ្ញវត្ថុលើកទី៨ ដើម្បីពិភាក្សាអំពីសេចក្តីព្រាងផែនការសកម្មភាពសម្រាប់រយៈពេល៣ឆ្នាំ របស់រាជរដ្ឋាភិបាលនិងក្រុមហ៊ុន CSD ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ព្រមទាំងជាប្រធានក្រុមការងារមណ្ឌលហិរញ្ញវត្ថុ។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាព ដែលជាសមាជិកក្រុមការងារ។

## វគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម" វគ្គទី២ ជូនមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារ



២៧.កាលពីថ្ងៃព្រហស្បតិ៍ ១០រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៩ ខែសីហា គ.ស. ២០២៤ និយ័តករ គណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សហការជាមួយអគ្គនាយកដ្ឋានពន្ធដារ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម" វគ្គទី២ ជូនមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដាររយៈពេល ៥ថ្ងៃនៅ អគារ៣៤៥។ វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម វគ្គបណ្តុះបណ្តាលនេះក៏មានការអញ្ជើញចូលរួមពី **ឯកឧត្តម កែន សម្បត្តិ** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម គង់ វិបុល រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ** និង**លោក សាយ សុខខេង** អគ្គនាយកក្រុមហ៊ុនឌីអេស្វស៊ី (DFC) ព្រមទាំង ថ្នាក់ដឹកនាំនិងមន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម ក្នុងនោះមានមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារសរុបចំនួន ៦៣នាក់។ វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងនៅក្នុងគោលដៅ

បញ្ញាបការយល់ដឹង និងសិក្សាលម្អិតលើបច្ចុប្បន្នភាពលក្ខខណ្ឌតម្រូវនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម ដែលជាមូលដ្ឋានក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងសម្រាប់ការចូលរួមអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្មដូចមានចែងក្នុងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ។

## សិក្ខាសាលាស្តីពី "ការអភិវឌ្ឍន៍គម្រោងវិនិយោគអាកាសធាតុសម្រាប់រយៈពេលវែងនៅកម្ពុជា



២៨.កាលពីថ្ងៃព្រហស្បតិ៍ ១០រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៩ ខែសីហា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេស អមដោយ **លោក ពេជ សុភាចារ** មន្ត្រីនៃនាយកដ្ឋានបច្ចេកទេស បានចូលរួមសិក្ខាសាលាស្តីពី "ការអភិវឌ្ឍន៍គម្រោងវិនិយោគអាកាសធាតុសម្រាប់រយៈពេលវែងនៅកម្ពុជា" សហការរៀបចំឡើងនិយ័តករមូលបត្រកម្ពុជា និងគណៈកម្មការសេដ្ឋកិច្ច និងសង្គមសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក របស់អង្គការសហប្រជាជាតិ (UNESCAP) នៅសណ្ឋាគារ Raffles Hotel Le Royal ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា ក្នុងគោលបំណងពិភាក្សាអំពីកាលានុវត្តភាព និងបញ្ហាប្រឈមក្នុងការបង្កើតបណ្តាញគម្រោងវិនិយោគបៃតងនៅប្រទេសកម្ពុជា។

## កិច្ចប្រជុំពិភាក្សាជាមួយវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ស្ថាប័ន ACCA និង សហព័ន្ធគណនេយ្យករអន្តរជាតិ




២៩.កាលពីថ្ងៃសុក្រ ១១ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ខែសីហា គ.ស. ២០២៤ ដោយបានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក ណុប សម្បត្តិ** អនុប្រធាននាយកដ្ឋាន អមដោយលោក **សេង ម៉េងហ័រ** មន្ត្រីជំនាញ នៃនាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម បានចូលរួមកិច្ចប្រជុំ

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

ពិភាក្សាជាមួយវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ស្ថាប័ន ACCA និង សហព័ន្ធគណនេយ្យករអន្តរជាតិ ស្តីពីលក្ខខណ្ឌតម្រូវដើម្បីក្លាយជាសមាជិកពេញសិទ្ធរបស់សហព័ន្ធគណនេយ្យករអន្តរជាតិតាមប្រព័ន្ធអនឡាញ (Microsoft Teams)។

## កិច្ចប្រជុំស្តីពី "ការរៀបចំខ្លឹមសារសម្រាប់វគ្គបណ្តុះបណ្តាលអំពីលក្ខន្តិកៈ របស់សហគ្រាសសាធារណៈ និងការគ្រប់គ្រងអាជីវកម្ម ជូនដល់រដ្ឋាករទឹកទាំង៩"




៣០.កាលពីថ្ងៃសុក្រ ១១រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ខែសីហា គ.ស.២០២៤ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក លី កុសល** អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមនៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអនុលោមភាព និង **លោកស្រី ពេជ្រ ម៉ានីឡា** អនុប្រធាននាយកដ្ឋានបច្ចេកទេស ព្រមទាំងមន្ត្រីជំនាញបានចូលរួមកិច្ចប្រជុំស្តីពី "ការរៀបចំខ្លឹមសារសម្រាប់វគ្គបណ្តុះបណ្តាលអំពីលក្ខន្តិកៈរបស់សហគ្រាសសាធារណៈនិងការគ្រប់គ្រងអាជីវកម្មជូនដល់រដ្ឋាករទឹកទាំង៩" ក្រោមការដឹកនាំរបស់ **ឯកឧត្តម យ៉េត វីណែល** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ វគ្គបណ្តុះបណ្តាលនេះគ្រោងរៀបចំក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងអំពី ការគ្រប់គ្រងហិរញ្ញវត្ថុនិងបង្កើនចំណេះដឹងលើការគ្រប់គ្រងអាជីវកម្ម ក្នុងន័យធានាឱ្យបាននូវអនុលោមភាពផ្នែកហិរញ្ញវត្ថុសាធារណៈ និងពង្រឹងប្រសិទ្ធភាពនៃអាជីវកម្មរបស់រដ្ឋាករទឹកទាំង៩។

## កម្មវិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករមូលបត្រកម្ពុជា និងសាជីវកម្ម



៣១.កាលពីថ្ងៃសុក្រ ១១រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ខែសីហា គ.ស. ២០២៤ នៅសាលប្រជុំជាន់ទី២ នៃអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យ និងសវនកម្ម **លោក ទឹម សត្យា** អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ បានអញ្ជើញចូលរួមកម្មវិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ គ្នារវាងនិយ័តករមូលបត្រកម្ពុជានិងសាជីវកម្មធានាឥណទានកម្ពុជាស្តីពី "កិច្ចសហប្រតិបត្តិការក្នុងការជំរុញការអភិវឌ្ឍន៍និងការបោះផ្សាយលក់សញ្ញាបណ្ណដែលមានការធានា" និងសិក្ខាសាលាស្តីពីអត្ថប្រយោជន៍ និងកាលានុវត្តភាពនៃការបោះផ្សាយលក់សញ្ញាបណ្ណដែលមានការ ធានានៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាលរបស់សាជីវកម្មធានាឥណទានកម្ពុជា។

## សិក្ខាសាលារួមគ្នាស្តីពី "ការរាយការណ៍ព័ត៌មានអំពីចីរភាព ការអនុវត្តសម្មតិកម្ម និងសក្តានុពល"



៣២.កាលពីថ្ងៃសុក្រ ១១រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ខែសីហា គ.ស.២០២៤ និយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំសិក្ខាសាលារួមគ្នាស្តីពី "ការរាយការណ៍ព័ត៌មានអំពីចីរភាព ការអនុវត្តសម្មតិកម្ម និងសក្តានុពល" សហការណ៍ជាមួយវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា និង CPA Australia ក្រោមអធីបតីភាព **ឯកឧត្តម ប៊ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម **លោក ឃុន ដារិទ្ធ** ប្រធានវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា និងលោកស្រី **Nguyen Thi Bich Hien** ( Regional Manager CPA Australia North Vietnam )។ សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងការត្រៀមខ្លួន និងការរៀបចំផែនការសកម្មភាពដើម្បីអនុវត្តស្តង់ដាការលាតត្រដាងព័ត៌មានអំពីចីរភាព IFRS S2 ដល់ភាគីពាក់ព័ន្ធ ជាពិសេសដើម្បីប្រមូលធាតុចូលនិងស្វែងយល់ផលប៉ះពាល់នៃការអនុវត្ត។ បទបង្ហាញនៅក្នុងសិក្ខាសាលានេះរួមមានប្រធានបទសំខាន់ៗចំនួន២ គឺ៖ (១) ទស្សនវិស័យនៃការអនុវត្តការរាយការណ៍ព័ត៌មានអំពីចីរភាព៖ ការចែករំលែកបទពិសោធន៍ពីទីផ្សារឈានមុខ បង្ហាញដោយ **លោកបណ្ឌិត Jonh Vong** ( CPA Aust. ) មកពីសាកលវិទ្យាល័យមូណាស់ នៃប្រទេសឥណ្ឌូនេស៊ី និង (២) ផលប្រយោជន៍ និងផលប៉ះពាល់ពីអនុវត្តការរាយការណ៍ព័ត៌មានអំពីចីរភាពនៅប្រទេសកម្ពុជា បង្ហាញដោយ **លោក ជេន ផាត** អគ្គនាយករងនៃនិយ័តករគណនេយ្យនិងសវនកម្ម។ ជាមួយគ្នានេះដែរ សិក្ខាសាលាក៏មានរៀបចំវេទិកាពិភាក្សាអំពីការត្រៀមលក្ខណៈនៃការអនុវត្តការរាយការណ៍ព័ត៌មានអំពីអំពីចីរភាពនៅកម្ពុជាដែលសម្របសម្រួលដោយ **លោក ជេន ផាត** និងជាវាគ្មិន ព្រមទាំងវាគ្មិនចំនួន៤រូប ទៀតរួមមាន៖ ១. លោកបណ្ឌិត **Jonh Vong** ( CPA Aust. ) ២. **លោក ជា ធួន** នាយកអប់រំនៃវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា ៣. **លោក Guelas Alalaid Emmanuel** មកពីក្រុមហ៊ុន EY កម្ពុជា និង ៤.**លោក ទេព ប៊ុនធឿន** មកពីធនាគារ អេស៊ីលីដា។

រៀបចំដោយ÷**លោក ឡាយ វិចិត្រ**

សម្របសម្រួលអត្ថបទ÷**កញ្ញា សុខ ណារី**

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម